១-ការបញ្ជូនតាមការផ្សាយជាសាធារណៈ នឹងមានអានុភាពនៅក្រោយអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃ ដែលបានបិទប្រកាសតាមបញ្ញត្តិនៃមាត្រា ២៥៦ (របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ) ខាងលើនេះ ។ ប៉ុន្តែ ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ នៃមាត្រា ២៥៥ (លក្ខខណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ) នៃក្រមនេះ នឹងមានអានុភាពនៅថ្ងៃបន្ទាប់ពីថ្ងៃបិទប្រកាស ។

២-ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដែលបានធ្វើឡើង សម្រាប់ការបញ្ជូនដែលត្រូវធ្វើនៅបរទេសវិញ អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺ ៦ (ប្រាំមួយ) សប្តាហ៍ ។

ជំពូកទី ៩
ការមើលសំណុំរឿង

មាត្រា ២៥៨.- ការទាមទារមើលសំណុំរឿងនៃបណ្តឹង ជាអាទិ៍

១-ភាគីនៃបណ្តឹង និង តតិយជនដែលធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងបណ្តឹង អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងបណ្តឹងពីក្រឡាការបាន ដោយបង់ពន្ធ ។ ចំពោះឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់

ឬ ឯកសារដកស្រង់នៃសំណុំរឿង ក្រឡាបញ្ជីត្រូវបញ្ជាក់ថាជាឯកសារ ចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារដកស្រង់ ហើយនិងចុះហត្ថលេខា ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្ត ចំពោះខ្សែអាត់ ខ្សែវីដេអូ ឬ វត្ថុដែលកត់ត្រាអំពីចំណុចដែលមានកំណត់ដោយវិធីប្រហែលគ្នា ក្នុងសំណុំរឿងឡើយ ។ ក្នុងករណីនេះ ប្រសិនបើមានការទាមទារពីសំណាក់ភាគីនៃបណ្តឹង ឬ តតិយជនដែលធ្វើសេចក្តីបញ្ជាក់ដំបូងថាមានការពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងបណ្តឹង តុលាការត្រូវអនុញ្ញាតឱ្យថតចម្លងវត្ថុទាំងនោះ ។

៣-ការទាមទារមើល ចម្លង ថតចម្លងនូវសំណុំរឿង មិនអាចធ្វើបានឡើយ បើការនោះធ្វើឱ្យមានឧបសគ្គដល់ការរក្សាទុកសំណុំរឿង ឬ ដល់ការបោត់ចែងការងាររបស់តុលាការ ។

គន្ថីទី ៣

បណ្តឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ២៥៩.– ប្រភេទនៃបណ្តឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់

១-ប្រភេទនៃបណ្តឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់ ចំពោះការសម្រេចសេចក្តីដែលមិនទាន់ចូលជាស្ថាពរ មានដូចខាងក្រោមនេះ :

ក-បណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រមរបស់សាលាដំបូង ឬ បណ្តឹងសាទុក្ខ ក្នុងករណីមានការព្រមព្រៀងរវាងភាគីដែលបានកំណត់នៅក្នុងចំណុច ក កថាខណ្ឌទី ១ នៃមាត្រា ២៦០ (សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បានជាអាទិ៍) នៃក្រមនេះ ។

ខ-បណ្តឹងសាទុក្ខ ចំពោះសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ។

គ-បណ្តឹងជំទាស់ ចំពោះដីកាសម្រេច ។

២-បណ្តឹងជំទាស់ អាចធ្វើឡើងបាន លុះត្រាតែមានបញ្ញត្តិក្នុងច្បាប់ ។

៣-ចំពោះដីកាសម្រេចលើបណ្តឹងជំទាស់ មិនអាចប្តឹងជំទាស់ទៀតបានឡើយ ។

ជំពូកទី ២

បណ្តឹងឧទ្ធរណ៍

មាត្រា ២៦០.– សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍

១-បណ្តឹងឧទ្ធរណ៍អាចធ្វើចំពោះសាលក្រមចុងក្រោយរបស់សាលាដំបូងបាន លើកលែងតែករណីដែលបានកំណត់ខាងក្រោមនេះ :

ក-គូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ដោយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខក្រោយពេលតុលាការបានចេញសាលក្រមចុងក្រោយ ។

ខ-សាលក្រមចុងក្រោយនោះវិនិច្ឆ័យទៅលើរឿងក្តីរូបិយវត្ថុ ឬ ពាណិជ្ជកម្មដែលមានតម្លៃកម្មវត្ថុនៃបណ្តឹង មិនលើសពី ៥.០០០.០០០ (ប្រាំលាន) រៀល ។

២-សេចក្តីព្រមព្រៀងដែលបានកំណត់នៅក្នុងចំណុច ក នៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ប្រសិនបើមិនបានធ្វើលិខិតជាលាយលក្ខណ៍អក្សរ ។

មាត្រា ២៦១.- ការកម្រិតបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី

ចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី មិនអាចប្តឹងឧទ្ធរណ៍ដោយឯករាជ្យតែឯកឯងបានឡើយ ។

មាត្រា ២៦២.- សេចក្តីសម្រេចដែលត្រូវទទួលការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍

សេចក្តីសម្រេចនៅមុនសាលក្រមចុងក្រោយ ត្រូវទទួលការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសេចក្តីសម្រេចដែលមិនអាចធ្វើឧបាស្រ័យបាន និង សេចក្តីសម្រេចដែលអាចធ្វើឧបាស្រ័យបានដោយការប្តឹងជំទាស់ ។

មាត្រា ២៦៣.- ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍

១-ភាគីអាចលះបង់ចោលនូវសិទ្ធិប្តឹងឧទ្ធរណ៍របស់ខ្លួនបាន ។

២-នៅក្រោយពេលបានប្តឹងឧទ្ធរណ៍រួចហើយ សេចក្តីថ្លែងការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាមួយគ្នានឹងការដកពាក្យបណ្តឹងឧទ្ធរណ៍ ។

មាត្រា ២៦៤.- អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍

១-បណ្តឹងឧទ្ធរណ៍ត្រូវធ្វើនៅក្នុងអំឡុងពេល ១ (មួយ) ខែ ដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬ ថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ។ ប៉ុន្តែ ករណីនេះមិនមែនជាការរារាំងលើអានុភាពនៃបណ្តឹងឧទ្ធរណ៍ដែលបានដាក់នៅមុនអំឡុងពេលនេះឡើយ ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យាបានឡើយ ។

ჯ

មាត្រា ២៦៥.- របៀបប្តឹងឧទ្ធរណ៍

១-ដើម្បីប្តឹងឧទ្ធរណ៍ ភាគីត្រូវដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការដើម ។ នៅក្នុងករណីនេះ តុលាការដើម ត្រូវផ្ញើឱ្យ បានឆាប់រហ័សនូវពាក្យបណ្តឹងឧទ្ធរណ៍ និងសំណុំរឿងទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ ។

២-ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សញ្ញាណសាលក្រមនៃការជំនុំជម្រះលើកទី ១ និង សេចក្តីថាប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ ។

គ-ក្នុងករណីដែលពុំបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ក្នុងពាក្យបណ្តឹងឧទ្ធរណ៍ទេ ដើមបណ្តឹងឧទ្ធរណ៍គប្បីដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលសរសេរអំពីចំណុចនោះ ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ នៅក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់តាំងពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍នោះ ។

មាត្រា ២៦៦.- សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍

១-ក្នុងករណីដែលពាក្យបណ្តឹងឧទ្ធរណ៍ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២៦៥ (របៀបប្តឹងឧទ្ធរណ៍) នៃក្រមនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវកំណត់អំឡុងពេលសមរម្យមួយ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនៅក្នុងអំឡុងពេលនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពន្ធសម្រាប់ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ មិនត្រូវបានបង់តាមបញ្ញត្តិនៃកថាខណ្ឌទី ៤ មាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) នៃក្រមនេះ ។

២-ករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើដើមបណ្តឹងឧទ្ធរណ៍មិនបានកែតម្រូវចំណុចខ្វះខាតនោះទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះ ដោយដីកាសម្រេច ។

៣-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើ អាចប្តឹងជំទាស់បាន ។

មាត្រា ២៦៧.- ការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍

១-ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនទៅចុងបណ្តឹងឧទ្ធរណ៍ ។

២-បញ្ញត្តិនៃមាត្រា ២៦៦ (សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមិនអាចបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍បាន រួមទាំងករណីដែលមិនបានបង់ជាមុននូវសោហ៊ុយចាំបាច់សម្រាប់បញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ ។

មាត្រា ២៦៨.- ការលើកចោលបណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់

ក្នុងករណីដែលបណ្តឹងឧទ្ធរណ៍មានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចលើកចោលបណ្តឹងឧទ្ធរណ៍នោះដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ដោយសាលដីកាបាន ។

មាត្រា ២៦៩.- ការដកពាក្យបណ្តឹងឧទ្ធរណ៍

១-បណ្តឹងឧទ្ធរណ៍អាចដកវិញបាន រហូតដល់ពេលដែលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវបានប្រកាស ។

២-ការដកពាក្យបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ការដកពាក្យបណ្តឹងឧទ្ធរណ៍នោះ អាចធ្វើឡើងដោយផ្ទាល់មាត់បាន ។

៣-ផ្នែកនៃបណ្តឹងឧទ្ធរណ៍ដែលត្រូវបានដកចេញ ត្រូវចាត់ទុកថាមិនបានចាត់ការតាំងពីដំបូងនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

៤-បញ្ញត្តិនៃមាត្រា ២១៩ (ការចាត់ទុកថាដកពាក្យបណ្តឹង) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចាត់ទុកថា ដកពាក្យបណ្តឹងឧទ្ធរណ៍ ។

មាត្រា ២៧០.- បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ

១-ចុងបណ្តឹងឧទ្ធរណ៍ ទោះជាសិទ្ធិប្តឹងឧទ្ធរណ៍នោះត្រូវបានរលត់ហើយក៏ដោយ ក៏

អាចប្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ រហូតដល់ពេលដែលការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវបានបញ្ចប់ ។

២-បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំត្រូវអស់អានុភាព នៅក្នុងករណីដែលពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវបានដក ឬ នៅក្នុងករណីដែលបណ្តឹងឧទ្ធរណ៍នោះត្រូវបានលើកចោលដោយសារមានភាពផ្ទុយនឹងច្បាប់ ។ ប៉ុន្តែ ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដែលមានល័ក្ខខ័ណ្ឌនៃបណ្តឹងឧទ្ធរណ៍គ្រប់គ្រាន់ ត្រូវចាត់ទុកថាជាបណ្តឹងឧទ្ធរណ៍ឯករាជ្យ ។

៣-បញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ។

មាត្រា ២៧១.- ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដោយតុលាការនៃបណ្តឹងឧទ្ធរណ៍

១-តុលាការនៃបណ្តឹងឧទ្ធរណ៍អាចប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រឹមតែផ្នែកដែលពុំមានពាក្យសុំប្តឹងឧទ្ធរណ៍ ចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ តាម ការពាក្យសុំ ដោយដីកាសម្រេច ។

២-ចំពោះការសម្រេចសេចក្តីរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍អំពីការអនុវត្តជាបណ្តោះអាសន្ន មិនអាចធ្វើឧទ្ធរណ៍បានឡើយ ។

មាត្រា ២៧២.- ទំហំនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាអាទិ៍

១-ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើ ត្រឹមតែក្នុងទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្តូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ តែប៉ុណ្ណោះ ។

២-ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងការជំនុំជម្រះលើកទី ១ ។

មាត្រា ២៧៣.- ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី ១

លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស បញ្ញត្តិនៃគន្ថីទី ២ (នីតិវិធីនៃការជំនុំជម្រះលើកទី ១) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះមាត្រា ៨០ (ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង) មាត្រា ១០៤

(ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ផ្នែកទី ៥ (សាលក្រមកំបាំងមុខ) ជំពូកទី ៥ នៃគន្ថីទី ២ និង ជំពូកទី ៧ (បទប្បញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិច) នៃគន្ថីទី ២ នៃក្រមនេះ ។

មាត្រា ២៧៤.- អានុភាពនៃសកម្មភាពបណ្តឹងនៅក្នុងការជំនុំជម្រះលើកទី ១ ជាអាទិ៍

១-សកម្មភាពបណ្តឹងដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី ១ មានអានុភាពក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

២-នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី ១ មានអានុភាពក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

មាត្រា ២៧៥.- ការកម្រិតនូវការអះអាងស្តីពីអសមត្ថកិច្ចក្នុងការជំនុំជម្រះលើកទី ១

នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ភាគីមិនអាចអះអាងអំពីអសមត្ថកិច្ចរបស់សាលាដំបូងបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសមត្ថកិច្ចផ្តាច់មុខ ។

មាត្រា ២៧៦.- ការដាក់ពាក្យបណ្តឹងតប

១-ការដាក់ពាក្យបណ្តឹងតបនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ អាចធ្វើបាន លុះត្រាតែមានការយល់ព្រមពីភាគីម្ខាងទៀត ។

២-បើភាគីម្ខាងទៀតមិនបានតវ៉ា តែបានធ្វើការទាញហេតុផលលើអង្គសេចក្តីអំពីការប្តឹងតប នោះត្រូវចាត់ទុកថា ភាគីនោះបានយល់ព្រមនឹងការដាក់ពាក្យបណ្តឹងតប ។

មាត្រា ២៧៧.- ការច្រានចោលបណ្តឹងឧទ្ធរណ៍

១-តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវច្រានចោលនូវបណ្តឹងឧទ្ធរណ៍ ក្នុងករណីដែលយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រឹមត្រូវ ។

២-ទោះជាក្នុងករណីដែលសំអាងហេតុនៃសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវក៏ដោយ ក៏តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវច្រានចោលនូវបណ្តឹងឧទ្ធរណ៍នោះដែរ បើយល់ឃើញថា សេចក្តីសម្រេចបញ្ចប់នៃសាលក្រមនោះ ត្រឹមត្រូវ ដោយផ្អែកលើសំអាងហេតុផ្សេងទៀត ។

មាត្រា ២៧៨.- ទំហំនៃការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១

ការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១ អាចធ្វើបាន ត្រឹមតែកម្រិតនៃឧបាស្រ័យ ដោយបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំតែប៉ុណ្ណោះ ។

មាត្រា ២៧៩.- ការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១

១-តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ក្នុងករណីដូចមានខាងក្រោមនេះ :

ក-បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ ។

ខ-បើនីតិវិធីនៅតុលាការជាន់ទី ១ នោះផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ ។

២-ក្នុងករណីដូចកថាខណ្ឌទី ១ ខាងលើនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការជំនុំជម្រះទៅលើបណ្តឹងនោះ លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ២៨០ (ការបញ្ជូនរឿងក្តីត្រឡប់ទៅវិញ) ឬ មាត្រា ២៨១ (ការផ្ទេរដោយមូលហេតុខុសសមត្ថកិច្ចផ្តាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១) នៃក្រមនេះ ។

មាត្រា ២៨០.- ការបញ្ជូនរឿងក្តីត្រឡប់ទៅវិញ

១-ក្នុងករណីដែលតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលលើកចោលបណ្តឹង ដោយយល់ឃើញថា បណ្តឹងនោះមិនត្រឹមត្រូវតាមច្បាប់ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនរឿងក្តីនោះ ត្រឡប់ទៅសាលាដំបូងវិញ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគ្មានការចាំបាច់ត្រូវទាញហេតុផលបន្ថែមទៀតអំពីរឿងក្តីនោះ ។

២-ក្រៅពីករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ បើមានភាពចាំបាច់ទាញហេតុផលបន្ថែមទៀត អំពីរឿងក្តីនោះ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចបញ្ជូនរឿងក្តីនោះត្រឡប់ទៅសាលាដំបូងវិញបាន ។

៣-ប្រសិនបើរឿងក្តីនោះត្រូវបានបញ្ជូនត្រឡប់ទៅវិញ ដោយសារមូលហេតុថា នីតិវិធីបណ្តឹងនៅសាលាដំបូងផ្ទុយនឹងច្បាប់ នីតិវិធីនៃបណ្តឹងនោះត្រូវចាត់ទុកថា បានលុបចោល ដោយសារការបញ្ជូនត្រឡប់ទៅវិញ ។

មាត្រា ២៨១.- ការផ្ទេរដោយមូលហេតុខុសសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១

ប្រសិនបើតុលាការនៃបណ្ដឹងឧទ្ធរណ៍លុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ដោយមូលហេតុថា រឿងក្ដីនោះ ខុសសមត្ថកិច្ចផ្ដាច់មុខ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវចេញសាលដីកាផ្ទេររឿងក្ដីនោះទៅតុលាការដែលមានសមត្ថកិច្ចវិញ ។

មាត្រា ២៨២.- ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នក្នុងសាលដីកានៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍

ចំពោះសាលដីកាអំពីការទាមទារសំណងជាប្រាក់ បើមានពាក្យសុំ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវប្រកាសថា សាលដីកាអាចអនុវត្តជាបណ្ដោះអាសន្នបានដោយពុំចាំបាច់ឱ្យដាក់ប្រាតិភោគ លើកលែងតែករណីដែលឃើញថា ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននោះមិនមានលក្ខណៈចាំបាច់ ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការនៃបណ្ដឹងឧទ្ធរណ៍អាចកំណត់ល័ក្ខខ័ណ្ឌឱ្យដាក់ប្រាតិភោគសម្រាប់ការអនុវត្តជាបណ្ដោះអាសន្ននោះបាន ។

ជំពូកទី ៣
បណ្ដឹងសាទុក្ខ

មាត្រា ២៨៣.- តុលាការនៃបណ្ដឹងសាទុក្ខ

១-បណ្ដឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលបាន ចំពោះសាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី ២ ដោយសាលាឧទ្ធរណ៍ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះសាលដីកាចុងក្រោយដែលសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី ១ តាមបញ្ញត្តិនៃច្បាប់ពិសេស ។

២-ចំពោះសាលក្រមចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី ១ ដោយសាលាដំបូង នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍នៅក្រោយពេលដែលតុលាការបានចេញសាលក្រមនោះ ដោយរក្សាទុកនូវសិទ្ធិប្ដឹងសាទុក្ខ បណ្ដឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលដោយផ្ទាល់បាន ។

មាត្រា ២៨៤.- មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខអាចធ្វើបាន ដោយយកមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើសាលដីកា ឬ សាលក្រម ។

មាត្រា ២៨៥.- មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ

១-ក្នុងករណីណាមួយដូចបានកំណត់ខាងក្រោមនេះ ត្រូវចាត់ទុកថា មានមូលហេតុនៃបណ្តឹងសាទុក្ខជាដរាប :

ក-តុលាការដែលចេញសាលដីកា ឬ សាលក្រម មិនត្រូវបានចាត់តាំង ដោយស្របទៅតាមច្បាប់ ។

ខ-ចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យចូលរួមក្នុងការចេញសាលដីកា ឬ សាលក្រម តែបានចូលរួម ។

គ-ភាពផ្ទុយនឹងបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ ។

ឃ-ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្តឹង ។

ង-ភាពផ្ទុយនឹងបញ្ញត្តិស្តីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ។

ច-សាលដីកា ឬ សាលក្រម គ្មានសំអាងហេតុ ឬ មានសំអាងហេតុ តែផ្ទុយនឹងគ្នា ។

២-បញ្ញត្តិនៃចំណុច ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការទទួលស្គាល់ពេលក្រោយ តាមបញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រា ៣៥ (វិធានការក្នុងករណីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹងជាអាទិ៍) ឬ កថាខណ្ឌទី ៣ នៃមាត្រា ៥៧ (វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង) នៃក្រមនេះ ។

មាត្រា ២៨៦.- ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍

បញ្ញត្តិនៃជំពូកទី ២ នៃគន្ថីទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងសាទុក្ខ និង នីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ លើកលែងតែមានបញ្ញត្តិពិសេស ។

មាត្រា ២៨៧.- របៀបប្តឹងសាទុក្ខ

ដើម្បីប្តឹងសាទុក្ខ ភាគីត្រូវដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការដើម ។ នៅក្នុងករណីនេះ តុលាការដើមត្រូវផ្ញើឱ្យបានឆាប់រហ័សនូវពាក្យបណ្តឹងសាទុក្ខ និង សំណុំរឿងទៅតុលាការនៃបណ្តឹងសាទុក្ខ ។

មាត្រា ២៨៨.- ការបញ្ជូនលិខិតទទួលពាក្យបណ្តឹងសាទុក្ខ ជាអាទិ៍

១-នៅក្នុងករណីដែលមានការដាក់ពាក្យបណ្តឹងសាទុក្ខ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនលិខិតទទួលពាក្យបណ្តឹងសាទុក្ខទៅភាគី លើកលែងតែក្នុងករណីដែលលើកចោលពាក្យបណ្តឹងសាទុក្ខនោះ ។

២-នៅពេលដែលតុលាការបញ្ជូនលិខិតទទួលពាក្យបណ្តឹងសាទុក្ខទៅចុងបណ្តឹងសាទុក្ខ ដោយយោលតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនទាំងពាក្យបណ្តឹងសាទុក្ខនៅជាមួយផង ។

មាត្រា ២៨៩.- ការសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ

១-ប្រសិនបើមិនបានសរសេរនូវមូលហេតុនៃបណ្តឹងសាទុក្ខក្នុងពាក្យបណ្តឹងសាទុក្ខទេ ដើមបណ្តឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនេះ ជូនទៅតុលាការនៃបណ្តឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូននូវលិខិតទទួលពាក្យបណ្តឹងសាទុក្ខ ។

២-ក្នុងករណីដែលបណ្តឹងសាទុក្ខធ្វើឡើង ដោយយកមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៨៤ (មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ) ខាងលើនេះ ដើមបណ្តឹងសាទុក្ខត្រូវសរសេរមូលហេតុនៃបណ្តឹងសាទុក្ខនេះ ដោយបញ្ជាក់អំពីបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត និង ហេតុដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តនោះ ។ នៅក្នុងករណីនេះ ប្រសិនបើហេតុនោះមានទំនាក់ទំនងនឹងនីតិវិធីនៃបណ្តឹង ត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់ នូវអង្គហេតុដែលផ្ទុយនោះ ។

៣-ក្នុងករណីដែលបណ្តឹងសាទុក្ខធ្វើឡើង ដោយយកមូលហេតុប្រាំពីរណាមួយ ដែលបានកំណត់នៅកថាខណ្ឌទី ១ នៃមាត្រា ២៨៥ (មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ) នៃក្រមនេះ ដើមបណ្តឹងសាទុក្ខត្រូវសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ ដោយបញ្ជាក់នូវ

4

ចំណុចក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៨៥ និង អង្គហេតុដែលត្រូវនឹងចំណុចនោះ ។

មាត្រា ២៩០.- ការលើកចោលបណ្តឹងសាទុក្ខ

ប្រសិនបើត្រូវនឹងចំណុចណាមួយខាងក្រោមនេះយ៉ាងជាក់ច្បាស់ តុលាការនៃបណ្តឹងសាទុក្ខ ត្រូវលើកចោលបណ្តឹងសាទុក្ខ ដោយដីកាសម្រេច :

ក-បើបណ្តឹងសាទុក្ខនោះមិនស្របច្បាប់ ហើយមិនអាចកែតម្រូវចំណុចខ្វះខាតនោះបាន ។

ខ-បើមិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២៨៩ (ការសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ) ខាងលើនេះ ឬ បើការសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ និងទី ៤ នៃមាត្រា ២៨៩ ។

មាត្រា ២៩១.- ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវ

១-ប្រសិនបើការសរសេរមូលហេតុទាំងមូលនៃបណ្តឹងសាទុក្ខ ដែលត្រូវបានបញ្ជាក់ក្នុងពាក្យបណ្តឹងសាទុក្ខ ឬ ក្នុងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ដែលត្រូវបានដាក់ក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៨៩ (ការសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ) នៃក្រមនេះ ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ និងទី ៣ នៃមាត្រា ២៨៩ នោះយ៉ាងជាក់ច្បាស់ តុលាការនៃបណ្តឹងសាទុក្ខ ត្រូវកំណត់អំឡុងពេលសមរម្យ ហើយបង្គាប់ឱ្យដើមបណ្តឹងសាទុក្ខកែតម្រូវនូវចំណុចខ្វះខាត ក្នុងអំឡុងពេលនោះ ដោយដីកាសម្រេច ។

២-ដីកាសម្រេចលើកចោលនូវបណ្តឹងសាទុក្ខដែលបានកំណត់ក្នុងចំណុច ខ នៃមាត្រា ២៩០ (ការលើកចោលនូវបណ្តឹងសាទុក្ខ) ខាងលើនេះ ត្រូវធ្វើឡើង ក្នុងករណីដែលដើមបណ្តឹងសាទុក្ខមិនបានធ្វើការកែតម្រូវនូវចំណុចខ្វះខាត នៅក្នុងអំឡុងពេលដែលបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ២៩២.- ការបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ

ប្រសិនបើតុលាការនៃបណ្តឹងសាទុក្ខមិនចេញដីកាសម្រេចលើកចោលបណ្តឹងសាទុក្ខ តាមបញ្ញត្តិនៃមាត្រា ២៩០ (ការលើកចោលនូវបណ្តឹងសាទុក្ខ) នៃក្រមនេះទេ តុលាការនៃ

បណ្តឹងសាទុក្ខត្រូវបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនោះទៅចុងបណ្តឹងសាទុក្ខ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតុលាការនៃបណ្តឹងសាទុក្ខជំនុំជម្រះ និង សម្រេចសេចក្តី ដោយពុំឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ហើយយល់ឃើញថា ពុំចាំបាច់បញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនោះ ។

មាត្រា ២៩៣.- ការបង្គាប់ឱ្យដាក់ឯកសារត្រៀម

តុលាការនៃបណ្តឹងសាទុក្ខអាចកំណត់អំឡុងពេលសមរម្យ ហើយបង្គាប់ឱ្យចុងបណ្តឹងសាទុក្ខដាក់ឯកសារត្រៀមលើកដំបូងបាន ។

មាត្រា ២៩៤.- ការច្រានចោលបណ្តឹងសាទុក្ខដោយមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់

តុលាការនៃបណ្តឹងសាទុក្ខអាចច្រានចោលបណ្តឹងសាទុក្ខដោយសាលដីកាបាន ដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ បើយល់ឃើញថា បណ្តឹងសាទុក្ខនោះគ្មានមូលហេតុ ក្រោយពីបានពិនិត្យពាក្យបណ្តឹងសាទុក្ខ លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដែលចុងបណ្តឹងសាទុក្ខបានដាក់លើកដំបូង ឬ ឯកសារផ្សេងទៀត ។

មាត្រា ២៩៥.- ទំហំនៃការស្រាវជ្រាវ

តុលាការនៃបណ្តឹងសាទុក្ខ ត្រូវធ្វើការស្រាវជ្រាវត្រឹមតែកម្រិតនៃឧបាស្រ័យ ដោយផ្អែកលើមូលហេតុនៃបណ្តឹងសាទុក្ខ ។

មាត្រា ២៩៦.- បំណងនៃអង្គហេតុស្ពាររបស់សាលដីកាដើម ឬ សាលក្រមដើម

១-អង្គហេតុដែលបានចូលជាស្ពារដោយត្រឹមត្រូវតាមច្បាប់ក្នុងសាលដីកាដើម ឬ សាលក្រមដើម ត្រូវមានចំណងចំពោះតុលាការនៃបណ្តឹងសាទុក្ខ ។

២-ក្នុងករណីដែលមានបណ្តឹងសាទុក្ខដែលយោលទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២៨៣ (តុលាការនៃបណ្តឹងសាទុក្ខ) នៃក្រមនេះ តុលាការនៃបណ្តឹងសាទុក្ខមិនអាចបដិសេធចោលសាលក្រមដើមឡើយ ដោយយកមូលហេតុថា ការចូលជាស្ពារនៃអង្គហេតុ

ក្នុងសាលក្រមដើមនោះ ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ។

មាត្រា ២៩៧.- ករណីលើកលែងនៃការអនុវត្តចំពោះចំណុចដែលស្រាវជ្រាវដោយឆន្ទានុសិទ្ធិ

បញ្ញត្តិនៃមាត្រា ២៩៥ (ទំហំនៃការស្រាវជ្រាវ) និង មាត្រា ២៩៦ (ចំណងនៃអង្គហេតុស្ថាពររបស់សាលដីកាដើម ឬ សាលក្រមដើម) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះចំណុចដែលតុលាការត្រូវស្រាវជ្រាវ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

មាត្រា ២៩៨.- ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

តុលាការនៃបណ្តឹងសាទុក្ខអាចប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន តាមពាក្យសុំ ដោយដីកាសម្រេចបាន ត្រឹមតែចំពោះផ្នែកដែលពុំមានឧបាស្រ័យនៅក្នុងសាលដីកាដើម ឬ សាលក្រមដើមតែប៉ុណ្ណោះ ។

មាត្រា ២៩៩.- ការបដិសេធចោល ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ជាអាទិ៍

១-នៅក្នុងករណីដែលមានមូលហេតុដែលបានកំណត់ក្នុងមាត្រា ២៨៤ (មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ) ឬ មាត្រា ២៨៥ (មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ) នៃក្រមនេះ តុលាការនៃបណ្តឹងសាទុក្ខត្រូវបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ហើយត្រូវបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការដើមវិញ ឬ ផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា លើកលែងតែក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៣០០ (ការបដិសេធចោល ហើយវិនិច្ឆ័យដោយខ្លួនឯង) នៃក្រមនេះ ។

២-តុលាការដែលបានទទួលរឿងក្តីដោយការបញ្ជូនត្រឡប់មកវិញ ឬ ការផ្ទេរតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើការសម្រេចសេចក្តីដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីម្តងទៀត ។ ក្នុងករណីនេះ សេចក្តីវិនិច្ឆ័យលើអង្គហេតុ និង អង្គច្បាប់ ដែលតុលាការនៃបណ្តឹងសាទុក្ខយកជាមូលហេតុនៃការបដិសេធចោល មានចំណងទៅលើតុលាការដែលបានទទួលការបញ្ជូន ឬ ការផ្ទេរ ។

៣-ចៅក្រមដែលបានចូលរួមក្នុងការសម្រេចសេចក្តីក្នុងសាលដីកាដើម ឬ សាលក្រមដើម មិនអាចចូលរួមក្នុងការសម្រេចសេចក្តីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះទេ ។

មាត្រា ៣០០.- ការបដិសេធចោល ហើយវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការសម្រេចសេចក្តីអំពីរឿងក្តីផ្ទាល់ដោយខ្លួនឯង ចំពោះករណីដូចខាងក្រោមនេះ :

ក-តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ដោយយកមូលហេតុថា តុលាការនៃការជំនុំជម្រះដើមមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ចំពោះអង្គហេតុ ដែលបានចូលជាស្ថាពរ ហើយតុលាការនៃបណ្តឹងសាទុក្ខអាចសម្រេចសេចក្តីអំពីរឿងក្តីនោះ ដោយផ្អែកលើអង្គហេតុនេះបាន ។

ខ-តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម ដោយយកមូលហេតុថា រឿងក្តីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ ។

ជំពូកទី ៤
បណ្តឹងជំនាស់

មាត្រា ៣០១.- របៀបប្តឹងជំទាស់

១-ដើម្បីប្តឹងជំទាស់ ភាគីត្រូវដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការដើម ។ នៅក្នុងករណីនេះ តុលាការដើម ត្រូវធ្វើឱ្យ បានឆាប់រហ័ស នូវពាក្យបណ្តឹងជំទាស់ និងសំណុំរឿង ទៅតុលាការនៃបណ្តឹងជំទាស់ ។

២-ក្នុងករណីដែលពុំបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរនូវដីកាសម្រេចដើម ក្នុងពាក្យបណ្តឹងជំទាស់ទេ ម្ចាស់បណ្តឹងជំទាស់គប្បីដាក់លិខិតជាលាយលក្ខណ៍អក្សរដែលសរសេរអំពីចំណុចនោះ ទៅតុលាការនៃបណ្តឹងជំទាស់ នៅក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់តាំងពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ ។

មាត្រា ៣០២.- បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ

១-ភាគីដែលមិនយល់ព្រមចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ

ចៅក្រមដែលទទួលការប្រគល់សិទ្ធិ អាចដាក់ពាក្យសុំប្តឹងតវ៉ាទៅតុលាការទទួលបណ្តឹងបាន តែក្នុងករណីដែលច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះជាដីកាសម្រេចរបស់តុលាការទទួលបណ្តឹង ។ ប៉ុន្តែ ក្នុងករណីដែលតុលាការទទួលបណ្តឹងជាតុលាការកំពូល ឬ សាលាឧទ្ធរណ៍ ភាគីអាចដាក់ពាក្យសុំប្តឹងតវ៉ាបាន លុះត្រាតែច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះជាដីកាសម្រេចរបស់សាលាដំបូង ។

២-ចំពោះដីកាសម្រេចលើពាក្យសុំនៃកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបណ្តឹងជំទាស់បាន ។

មាត្រា ៣០៣.- អំឡុងពេលសម្រាប់ប្តឹងជំទាស់

១-បណ្តឹងជំទាស់ត្រូវធ្វើក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច ។

២-អំឡុងពេលនៃកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

មាត្រា ៣០៤.- ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ

១-បញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ និង នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់លើដីកាសម្រេចរបស់សាលាដំបូង និង នីតិវិធីនៃតុលាការនៃបណ្តឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈបណ្តឹង ឬ នីតិវិធីនោះ ។

២-បញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីទាក់ទងនឹងការជំនុំជម្រះបណ្តឹងសាទុក្ខនោះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់លើដីកាសម្រេចដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ និង នីតិវិធីទាក់ទងនឹងបណ្តឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្តឹង ឬ នីតិវិធីនោះ ។

មាត្រា ៣០៥.- ការផ្អាកអានុភាពនៃដីកាសម្រេចដើម

១-បណ្តឹងជំទាស់ត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើម ។

២-តុលាការនៃបណ្តឹងជំទាស់ ឬ តុលាការដែលបានចេញដីកាសម្រេចដើម អាច

បង្គាប់ឱ្យផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចដើម ឬ បង្គាប់ឱ្យចាត់ចែងជាចាំបាច់ផ្សេងទៀតបាន រហូតដល់ពេលមានដីកាសម្រេចអំពីបណ្តឹងជំទាស់ ។

មាត្រា ៣០៦.- ការទាញហេតុផលដោយផ្ទាល់មាត់តាមឆន្ទៈស្ម័គ្រចិត្ត និង ការសួរជំនួសការទាញហេតុផល ដោយផ្ទាល់មាត់

១-ការសម្រេចសេចក្តីលើបណ្តឹងជំទាស់ អាចធ្វើបាន ដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ។

២-ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់មិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់អំពីបណ្តឹងជំទាស់ទេ តុលាការអាចធ្វើការសួរម្ចាស់បណ្តឹងជំទាស់ ឬ អ្នកផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍នៃបណ្តឹងបាន ។

គន្ថីទី ៤
ការជំនុំជម្រះសាជាថ្មី

ជំពូកទោល
ការជំនុំជម្រះសាជាថ្មី

មាត្រា ៣០៧.- មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)

១-ភាគីអាចស្នើសុំប្តឹងឧបាស្រ័យ តាមបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ចំពោះសាលក្រមចុងក្រោយ ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរហើយ ក្នុងករណីដែលមានមូលហេតុណាមួយដូចរៀបរាប់ខាងក្រោមនេះ :

ក-បើពុំបានបាត់តាំងតុលាការដែលបានចេញសាលក្រម ឬ សាលដីកា ទៅតាមច្បាប់កំណត់ ។

ខ-បើចៅក្រមដែលពុំអាចចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកាតាមច្បាប់ បានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកានោះ ។

គ-បើខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ឬ ខ្វះសិទ្ធិតំណាងដោយអាណត្តិ ។

ឃ-បើចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកា បានប្រព្រឹត្តអំពើល្មើសដែលពាក់ព័ន្ធនឹងមុខងាររបស់ខ្លួនចំពោះរឿងក្តី ។

ង-បើភាគីបានសារភាព ឬ ត្រូវបានរារាំងក្នុងការដាក់មធ្យោបាយតទល់ ឬ ការការពារខ្លួនដែលមានឥទ្ធិពលដល់សាលក្រម ឬ សាលដីកា ដោយសារបទល្មើសរបស់អ្នកដទៃ ។

ច-បើឯកសារ ឬ វត្ថុឯទៀតដែលបានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា ត្រូវបានក្លែង ឬ កែប្រែដោយបន្លំ ។

ឆ-បើសេចក្តីថ្លែងការណ៍មិនពិតរបស់សាក្សី អ្នកធ្វើកោសលវិច័យ អ្នកបកប្រែ ភាគីដែលបានធ្វើសម្បថ ឬ របស់អ្នកតំណាងដែលច្បាប់បានកំណត់ដែលបានធ្វើសម្បថ បានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា ។

ជ-បើសាលក្រម ឬ សាលដីកា ឬ សេចក្តីសម្រេចឯទៀត ផ្នែករដ្ឋប្បវេណី ឬ ផ្នែកព្រហ្មទណ្ឌ ឬ ការចាត់ចែងផ្នែករដ្ឋបាល ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកាត្រូវបានផ្លាស់ប្តូរ ដោយសារសេចក្តីសម្រេច ឬ ការចាត់ចែងផ្នែករដ្ឋបាលនៅពេលក្រោយ ។

ឈ-បើមានការភ្លេចបញ្ចូលសេចក្តីវិនិច្ឆ័យលើចំណុចសំខាន់ៗ ដែលអាចមានឥទ្ធិពលទៅលើសាលក្រម ឬ សាលដីកា ។

ញ-បើសាលក្រម ឬ សាលដីកា ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានការប៉ះពាល់ដល់សាលក្រម ឬ សាលដីកាមុនដែលបានចូលជាស្ថាពរហើយ ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីបានធ្វើការអះអាងពីមូលហេតុនោះ នៅពេលធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ឬ ភាគីបានដឹងអំពីមូលហេតុនេះហើយតែមិនធ្វើការអះអាង ។

២-ចំពោះមូលហេតុដែលបានកំណត់ពីចំណុច ឃ រហូតដល់ចំណុច ង នៃកថាខណ្ឌទី ១ ខាងលើនេះ ភាគីអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន លុះត្រាតែមានករណីដូចបានរៀបរាប់ខាងក្រោមនេះ :

ក-ករណីដែលសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោស ឬ សេចក្តីសម្រេចដាក់ប្រាក់ពិន័យបានចូលជាស្ថាពរចំពោះអំពើដែលត្រូវដាក់ទណ្ឌកម្ម ។

ខ-ករណីដែលមិនអាចទទួលបាននូវសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោសជាស្ថាពរ ឬ សេចក្តីសម្រេច ដែលដាក់ប្រាក់ពិន័យជាស្ថាពរ ដោយសារមូលហេតុផ្សេងពីមូលហេតុថា គ្មានភស្តុតាង ។

៣-បើសាលដីកាសម្រេចអង្គសេចក្តីអំពីរឿងក្តី ត្រូវបានសម្រេចនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍រួចហើយ ភាគីមិនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រមរបស់តុលាការនៃការជំនុំជម្រះលើកទី ១ បានឡើយ ។

មាត្រា ៣០៨.- មូលហេតុនៃការជំនុំជម្រះសាជាថ្មី (ពីរ)

ក្នុងករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) ខាងលើនេះ ចំពោះសេចក្តីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ទោះជាមានការកំណត់នូវមធ្យោបាយនៃឧបាស្រ័យ

ដោយឯកឯងចំពោះសេចក្តីសម្រេចនោះក៏ដោយ ក៏ភាគីអាចយកមូលហេតុនោះមកធ្វើជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកានោះបានដែរ ។

មាត្រា ៣០៩.- តុលាការនៃការជំនុំជម្រះសាជាថ្មី

១-បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដែលបានចេញសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មីនោះ ។

២-បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកាអំពីរឿងក្តីតែមួយដែលត្រូវបានចេញដោយតុលាការច្រើនដែលមានថ្នាក់ខុសគ្នា តុលាការជាន់ខ្ពស់មានសមត្ថកិច្ចរួមលើសាលក្រម ឬ សាលដីកាទាំងនោះ ។

៣-ចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ពុំអាចចូលរួមក្នុងការជំនុំជម្រះ និងសម្រេចសេចក្តីអំពីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះបានឡើយ ។

មាត្រា ៣១០.- នីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី

បញ្ញត្តិស្តីពីនីតិវិធីបណ្តឹងទៅតាមលំដាប់ថ្នាក់នៃការជំនុំជម្រះនីមួយៗ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី លើកលែងតែបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្តឹងនៃការជំនុំជម្រះសាជាថ្មី ។

មាត្រា ៣១១.- អំឡុងពេលនៃការជំនុំជម្រះសាជាថ្មី

១-បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវធ្វើនៅក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលភាគីបានដឹងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ក្រោយពេលដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរហើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលយកមូលហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ ចំណុច ញ កថាខណ្ឌទី ១ នៃមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) នៃក្រមនេះ ។

៚

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

៣-ភាគីពុំអាចប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានឡើយ ប្រសិនបើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងផុត ដោយគិតពីថ្ងៃដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ឬ គិតពីថ្ងៃដែលមូលហេតុនៃការជំនុំជម្រះសាជាថ្មីកើតឡើង ក្នុងករណីដែលមូលហេតុនោះកើតឡើងក្រោយពេលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលយកមូលហេតុដែលបានកំណត់នៅក្នុងចំណុច គ ឬ ចំណុច ញ កថាខណ្ឌទី ១ នៃមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) នៃក្រមនេះ ។

មាត្រា ៣១២.- ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

១-នៅក្នុងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សញ្ញាណនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និងសេចក្តីទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកានោះ ។

គ-អង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី ។

២-ឯកសារចម្លងនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវភ្ជាប់ជាមួយនឹងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។

មាត្រា ៣១៣.- ការកែប្រែមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ភាគីដែលបានដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចកែប្រែមូលហេតុនៃការជំនុំជម្រះសាជាថ្មីបាន ។

មាត្រា ៣១៤.- ការលើកចោលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង ការច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី

១-ក្នុងករណីដែលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានភាពផ្ទុយនឹងច្បាប់ តុលាការត្រូវលើកចោលបណ្តឹងនោះ ដោយដីកាសម្រេច ។

២-ក្នុងករណីដែលគ្មានមូលហេតុនៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយដីកាសម្រេច ។

៣-ប្រសិនបើដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ចូលជាស្ថាពរហើយ ភាគីមិនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៀត ដោយយកមូលហេតុដូចគ្នាបានឡើយ ។

៤-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

មាត្រា ៣១៥.- ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី

១-ក្នុងករណីដែលមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវចេញដីកាសម្រេចដើម្បីចាប់ផ្តើមធ្វើការជំនុំជម្រះសាជាថ្មី ។

២-តុលាការត្រូវសួរភាគីម្ខាងទៀតជាមុន ក្នុងករណីចេញដីកាសម្រេចដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

មាត្រា ៣១៦.- ការវិនិច្ឆ័យ និង សម្រេចសេចក្តីលើអង្គសេចក្តី

១-តុលាការត្រូវធ្វើការវិនិច្ឆ័យ និង សម្រេចសេចក្តីលើអង្គសេចក្តី តាមទំហំនៃឧបាស្រ័យ នៅក្នុងករណីដែលដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីចូលជាស្ថាពរ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថា សាលក្រម ឬ សាលដីកាត្រឹមត្រូវ តុលាការត្រូវច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ ។

៣-លើកលែងតែក្នុងករណីដូចកថាខណ្ឌទី ២ ខាងលើនេះ តុលាការត្រូវលុបចោលនូវសាលក្រម ឬ សាលដីកា ហើយត្រូវសម្រេចសេចក្តីជាថ្មីទៀត ។

មាត្រា ៣១៧.- ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច

១-ចំពោះដីកាសម្រេចដែលអាចប្តឹងឧបាស្រ័យដោយបណ្តឹងជំទាស់ ហើយបានចូលជាស្ថាពរ អាចដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីបាន ។

២-បញ្ញត្តិចាប់ពីមាត្រា ៣០៧ (មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)) រហូតដល់មាត្រា ៣១៦ (ការវិនិច្ឆ័យ និង សម្រេចសេចក្តីលើអង្គសេចក្តី) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ៣១៨.- បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយតតិយជន

១-បើដើមចោទ និង ចុងចម្លើយបានទទួលនូវសាលក្រម ឬ សាលដីកា ដោយរួមគំនិតគ្នាក្នុងគោលបំណងធ្វើឱ្យបាត់បង់សិទ្ធិ ឬ ផលប្រយោជន៍របស់តតិយជន តតិយជននោះអាចធ្វើឧបាស្រ័យ ដោយបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរនោះបាន ។

២-បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដើមចោទ និង ចុងចម្លើយ ត្រូវក្លាយជាសហចុងចម្លើយ ។

៣-បញ្ញត្តិនៃមាត្រា ៤១ (បទបញ្ញត្តិពីការវិនិច្ឆ័យលើសហបណ្តឹងចាំបាច់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះជនដែលជាសហចុងចម្លើយតាមកថាខណ្ឌទី ២ ខាងលើ និង តតិយជនដែលបានដាក់ពាក្យបណ្តឹង ទាមទារឱ្យជំនុំជម្រះសាជាថ្មីតាមកថាខណ្ឌទី ១ ខាងលើនេះ ។

គន្ថីទី ៥
នីតិវិធីដាស់តឿន

ជំពូកទោល
នីតិវិធីដាស់តឿន

មាត្រា ៣១៩.- លក្ខខ័ណ្ឌនៃដីកាសម្រេចដាស់តឿន

ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ តុលាការអាចចេញដីកាសម្រេចដាស់តឿន តាមពាក្យសុំរបស់ម្ចាស់បំណុលបាន ។ ប៉ុន្តែ ករណីនេះអាចធ្វើទៅបាន លុះត្រាតែអាចធ្វើការបញ្ជូនដីកានោះនៅព្រះរាជាណាចក្រកម្ពុជាបាន តាមវិធីក្រៅពីការបញ្ជូនតាមការផ្សាយជាសាធារណៈ ។

មាត្រា ៣២០.- ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន

១-ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនចំពោះកូនបំណុលដូចមានកំណត់ក្នុងចំណុចខាងក្រោម ត្រូវធ្វើទៅសាលាដំបូងដែលមានសមត្ថកិច្ចលើតំបន់ដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-រូបវន្តបុគ្គល : លំនៅឋាន ឬ បើពុំមានលំនៅឋាន ឬ អានលំនៅឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ គឺទីសំណាក់ ។

ខ-នីតិបុគ្គលក្នុងប្រទេស : ទីស្នាក់ការកណ្ដាល ឬ ទីកន្លែងអាជីវកម្មចម្បង ឬ បើពុំមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មទេ គឺលំនៅឋានរបស់អ្នកតំណាង ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បង ។

គ-នីតិបុគ្គលបរទេស : ទីស្នាក់ការកណ្ដាល ឬ ទីកន្លែងអាជីវកម្មចម្បងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ បើពុំមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ គឺលំនៅឋានរបស់អ្នកតំណាងប្រចាំព្រះរាជាណាចក្រកម្ពុជា ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនអំពីការទាមទារដែលបានកំណត់ក្នុង

ចំណុចខាងក្រោមនេះ អាចធ្វើទៅសាលាដំបូងដែលមានសមត្ថកិច្ចលើតំបន់ដែលបាន កំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះបានដែរ :

ក-ការទាមទារចំពោះបុគ្គលដែលមានទីស្នាក់ការ ឬ កន្លែងអាជីវកម្ម ហើយការទាមទារនោះទាក់ទងនឹងការងារនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ : កន្លែងដែលមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ ។

ខ-ការទាមទារឱ្យសងជាប្រាក់ដោយរូបិយាណត្តិ ឬ មូលប្បទានប័ត្រ និង ការទាមទារបន្ទាប់បន្សំដែលទាក់ទងនឹងវត្ថុទាំងនេះ : កន្លែងដែលត្រូវសងរូបិយាណត្តិ ឬ មូលប្បទានប័ត្រនោះ ។

២-សមត្ថកិច្ចដែលកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ គឺជាសមត្ថកិច្ចផ្តាច់មុខ ។

មាត្រា ៣២១.- ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹង

បញ្ញត្តិស្តីពីបណ្តឹង ត្រូវយកមកអនុវត្តដូចគ្នាដែរ ចំពោះពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន លុះត្រាតែគ្មានភាពផ្ទុយនឹងលក្ខណៈរបស់ពាក្យសុំនោះ ។

មាត្រា ៣២២.- ការលើកចោលនូវពាក្យសុំ

ក្នុងករណីដែលពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន មានភាពផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៣១៩ (ល័ក្ខខ័ណ្ឌនៃដីកាសម្រេចដាស់តឿន) ឬ មាត្រា ៣២០ (ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន) ខាងលើនេះ ឬ ក្នុងករណីដែលមានភាពច្បាស់លាស់ថា គ្មានមូលហេតុក្នុងការទាមទារ ដោយគិតអំពីខ្លឹមសារនៃពាក្យសុំទេ តុលាការត្រូវលើកចោលពាក្យសុំនេះ ដោយដីកាសម្រេច ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដែរ ចំពោះការទាមទារមួយភាគដែលមិនអាចចេញដីកាសម្រេចដាស់តឿនភាគនោះ ។

មាត្រា ៣២៣.- ការចេញដីកាសម្រេចដាស់តឿន ជាអាទិ៍

១-ដីកាសម្រេចដាស់តឿន ត្រូវចេញដោយមិនចាំបាច់សួរកូនបំណុល ។

២-កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ទៅតុលាការដែលបានចេញដីកាសម្រេចនោះបាន ។

មាត្រា ៣២៤.- ចំណុចដែលត្រូវសរសេរបញ្ជាក់ក្នុងដីកាសម្រេចដាស់តឿន

១-ដីកាសម្រេចដាស់តឿន ត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ដីកាសម្រេចដែលម្ចាស់បំណុលទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារនេះ ។

គ-សេចក្តីបង្គាប់ឱ្យសងជាប្រាក់ដែលមានកំណត់នូវចំនួន ។

២-ក្នុងដីកាសម្រេចដាស់តឿននៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរបន្ថែមថា បើកូនបំណុលមិនបានដាក់ពាក្យប្តឹងតវ៉ាការដាស់តឿន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ បន្ទាប់ពីបានទទួលការបញ្ជូននូវដីកាសម្រេចដាស់តឿននេះទេ នោះតុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

មាត្រា ៣២៥.- ការបញ្ជូនដីកាសម្រេចដាស់តឿន

១-តុលាការត្រូវជូនដំណឹងអំពីដីកាសម្រេចដាស់តឿនទៅឱ្យម្ចាស់បំណុល ហើយត្រូវបញ្ជូនដីកាសម្រេចនោះ ទៅកូនបំណុលផងដែរ ។

២-ដីកាសម្រេចដាស់តឿននេះត្រូវមានអានុភាព នៅពេលដែលបានបញ្ជូនទៅដល់កូនបំណុល ។

៣-ប្រសិនបើមិនអាចបញ្ជូនដីកាសម្រេចដាស់តឿន ដោយសារគ្មានលំនៅឋាន ទីសំណាក់ ទីស្នាក់ការ ទីកន្លែងអាជីវកម្ម របស់កូនបំណុល ឬ លំនៅឋានរបស់អ្នកទទួលបន្ទុកការកិច្ចការងារចម្បង នៅទីកន្លែងដែលម្ចាស់បំណុលបានរាយការណ៍ទេ តុលាការត្រូវជូនដំណឹងអំពីហេតុការណ៍នេះទៅម្ចាស់បំណុល ។ ក្នុងករណីនេះ ប្រសិនបើម្ចាស់បំណុលមិនបានរាយការណ៍អំពីទីកន្លែងដែលត្រូវបញ្ជូន ក្រៅពីទីកន្លែងដែលខ្លួនបានរាយការណ៍ពីមុន ក្នុងអំឡុងពេល ២ (ពីរ) ខែ ដោយគិតចាប់ពីថ្ងៃដែលម្ចាស់បំណុលទទួលដំណឹង ត្រូវចាត់ទុកថា ម្ចាស់បំណុលនោះបានដកពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនវិញ ។

4

៤-អំឡុងពេលដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

មាត្រា ៣២៦.- ការលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចផាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

១-ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ាចំពោះដីកាសម្រេចផាស់តឿនដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន មិនស្របច្បាប់ទេ តុលាការត្រូវលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចផាស់តឿននោះ ដោយដីកាសម្រេច ។

២-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

មាត្រា ៣២៧.- អានុភាពនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចផាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

១-ប្រសិនបើមានពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចផាស់តឿន នៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដីកាសម្រេចផាស់តឿននោះ ត្រូវបាត់បង់អានុភាពក្នុងទំហំនៃការតវ៉ានោះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះការទាមទារដែលទាក់ទងនឹងការតវ៉ាចំពោះដីកាសម្រេចផាស់តឿន ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្តឹងនៅតុលាការដែលបានកំណត់នៅមាត្រា ៣២០ (ពាក្យសុំឱ្យចេញដីកាសម្រេចផាស់តឿន) នៃក្រមនេះ នៅពេលដែលមានពាក្យសុំឱ្យចេញដីកាសម្រេចផាស់តឿន ។ ក្នុងករណីនេះ ប្រាក់សោហ៊ុយសម្រាប់នីតិវិធីផាស់តឿន គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្តី ។

មាត្រា ៣២៨.- ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

១-ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចផាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍បន្ទាប់ពីថ្ងៃដែលបានទទួលការបញ្ជូនដីកាសម្រេចផាស់តឿន ឬ បើដីកាសម្រេចដែលលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចផាស់តឿន មុនការប្រកាសឱ្យអនុវត្តជាបណ្តោះ

អាសន្នបានចូលជាស្ថាពរ តុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយកំណត់បញ្ជាក់បន្ថែមនូវប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿនលើដីកាសម្រេចដាស់តឿនដោយឆន្ទានុសិទ្ធិ ។

២-ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវបញ្ជាក់នៅក្នុងដីកាសម្រេចដាស់តឿន ហើយត្រូវបញ្ជូនទៅភាគី ។

៣-បញ្ញត្តិនៃមាត្រា ១៩៧ (ការបោះបង់អានុភាពនៃការប្រកាសឱ្យអនុវត្តជាបណ្តោះ-អាសន្ន និង បដិទានស្ថានភាពដើម) និង កថាខណ្ឌទី ២ នៃមាត្រា ៣២៥ (ការបញ្ជូនដីកាសម្រេចដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ៣២៩.- ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

១-ពាក្យសុំតវ៉ាការដាស់តឿននៃកថាខណ្ឌទី ២ មាត្រា ៣២៣ (ការចេញដីកាសម្រេចការដាស់តឿន ជាអាទិ៍) នៃក្រមនេះ ចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវធ្វើនៅក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ក្រោយពីបានទទួលការបញ្ជូនដីកាសម្រេចដាស់តឿននោះ ។

២-អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

មាត្រា ៣៣០.- ការលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

១-ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះមិនស្របច្បាប់ទេ តុ-លាការត្រូវលើកចោលពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿននោះ ដោយដីកាសម្រេច ។

២-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំ-ទាស់បាន ។

មាត្រា ៣៣១.– ការផ្ទេរនីតិវិធីផាស់តឿនទៅនីតិវិធីនៃបណ្តឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចផាស់តឿនដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

ប្រសិនបើមានពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចផាស់តឿន នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ការទាមទារដែលទាក់ទងនឹងការតវ៉ាចំពោះដីកាសម្រេចផាស់តឿន ត្រូវចាត់ទុកថា បានដាក់ពាក្យបណ្តឹងទៅតុលាការដែលបានចេញដីកាសម្រេចផាស់តឿននោះ នៅពេលដែលមានពាក្យសុំឱ្យចេញដីកាសម្រេចផាស់តឿន ។ ក្នុងករណីនេះ ប្រាក់សោហ៊ុយសម្រាប់នីតិវិធីផាស់តឿន គឺជាផ្នែកមួយនៃប្រាក់ប្រដាប់ក្តី ។

មាត្រា ៣៣២.– សាលក្រមនៃបណ្តឹងដែលត្រូវបានផ្ទេរ នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

១-ប្រសិនបើសាលក្រមនៃបណ្តឹងដែលត្រូវបានផ្ទេរ តាមបញ្ញត្តិនៃមាត្រា ៣៣១ (ការផ្ទេរនីតិវិធីផាស់តឿនទៅនីតិវិធីនៃបណ្តឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចផាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន) ខាងលើនេះ ស្របគ្នានឹងដីកាសម្រេចផាស់តឿននោះ តុលាការត្រូវទទួលស្គាល់នូវដីកាសម្រេចផាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ក្នុងសាលក្រមនេះ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលនីតិវិធីផាស់តឿនត្រូវបានធ្វើឡើងដោយខុសច្បាប់ ។

២-ក្នុងសាលក្រមនៃបណ្តឹងដែលត្រូវបានផ្ទេរ តាមបញ្ញត្តិនៃមាត្រា ៣៣១ (ការផ្ទេរនីតិវិធីផាស់តឿនទៅនីតិវិធីនៃបណ្តឹង ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចផាស់តឿនដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន) នៃក្រមនេះ តុលាការត្រូវលុបចោលនូវដីកាសម្រេចផាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអា-សន្ន លើកលែងតែក្នុងករណីដែលតុលាការទទួលស្គាល់នូវដីកាសម្រេចផាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

មាត្រា ៣៣៣.- អានុភាពនៃដីកាសម្រេចផាស់តឿន

ប្រសិនបើគ្មានពាក្យសុំតវ៉ាចំពោះដីកាសម្រេចផាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬ ប្រសិនបើដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចផាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នបានចូលជាស្ថាពរ ដីកាសម្រេចផាស់តឿននោះនឹងមានអានុភាពដូចសាលក្រមស្ថាពរដែរ ។

តទៅរាជកិច្ចលេខ ៥៧

នស/រកត/០៧០៦/៣៦៩

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដាក់អោយចូលនិវត្តន៍ នាយនគរបាលជាតិជាន់ខ្ពស់ ថ្នាក់ឧត្តមសេនីយ៍ចំនួន ០២រូប នៃក្រសួងមហាផ្ទៃដូចមានរាយនាមខាងក្រោម :

១- ឧត្តមសេនីយ៍ឯក **ហ៊ឹម នន** អត្តលេខ ០០៣០

២- ឧត្តមសេនីយ៍ត្រី **ជុំ ឃាត** អត្តលេខ ០៣៤១ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍អោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.០៦០៧.៣៤០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦

លេខ : ៣០៤. ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកត/០៧០៦/៣២១

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដាយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបញ្ចប់តំណែងឯកឧត្ដមឧត្ដមសេនីយ៍ទោ ហេង ពៅ អត្តលេខ ០៣៤០ ពីអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងពីទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្ដម សីហមុនី

លេខ : ៩៧០៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យ៉ុន ជិនកេន

៣រល.០៦០៧.៣៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៦

ព្រះរាជក្រឹត្យ

នស/រកត/០៧០៦/៣២២

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្ដិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានបញ្ចប់មុខតំណែងអនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម ÷

១. ឯកឧត្ដម **សៅ សុភខុន**

២. ឯកឧត្ដម **ឡូ គឹមឆោវ**

មាត្រា ២.-

ត្រូវបានតែងតាំងឱ្យកាន់មុខតំណែងជាអនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម ÷

១. ឯកឧត្ដម **តែ គុយសេង** ជំនួស ឯកឧត្ដម **សៅ សុភខុន**

២. ឯកឧត្ដម **ជូ យិនស៊ីម** ជំនួស ឯកឧត្ដម **ឡូ គឹមឆោវ**

មាត្រា ៣.~

ត្រូវបានតែងតាំងឯកឧត្តម **សៅ សុភខុន** ជាទីប្រឹក្សាអមក្រសួងសុខាភិបាល មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ៤.~

ត្រូវបានតែងតាំងឯកឧត្តម **កើត មឿច** ជាអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាលជំនួសឯកឧត្តម **តែ គុយសៀង** ។

មាត្រា ៥.~

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦.~

សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៧.~

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្ដម សីហមុនី

នស-០៧០៦.៣៤៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦

លេខ : ៣០៥.ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០០៦

អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

នស/រកត/០៧០៦/៣២៣

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងលោកជំទាវ **នន ចំន្ទថន** ជាទីប្រឹក្សាអមក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល-០៦០៧.៣៤៤

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៦

លេខ : ៣០៧៦.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុំ ជិនកេន

នស/រកត/០៧០៦/៣៦៤

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋារាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្លាស់ឯកឧត្តម កែម មង្គល បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសឹង្ហបូរី ឱ្យមកបម្រើការងារក្នុងប្រទេសវិញ ដោយចប់អាណត្តិបេសកកម្ម ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៦០៧.៣៤៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦

លេខ : ៣០៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកត/០៧០៦/៣២៥

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្ដេច ព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងលោកជំទាវ *ស៊ុន ស៊ី* បច្ចុប្បន្នអគ្គលេខាធិការរងរាជរដ្ឋាភិបាល ជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសិង្ហបុរី ។

មាត្រា ២ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៣រល-០៦០៧.៣៤៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី *២៧* ខែ *កក្កដា* ឆ្នាំ២០០៦

លេខ : ៣០៧៦.ល
... ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ កក្កដា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៦/៣៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម ឡេង ធនយុទ្ធា ជាទីប្រឹក្សាអមរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២: ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម អ៊ឹង ជុនហួរ ឱ្យបំពេញមុខងារជាអគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូន ជំនួសឯកឧត្តម ឡេង ធនយុទ្ធា ដែលត្រូវទទួលភារកិច្ចថ្មី ។

មាត្រា ៣: រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៦-០៦០៧.៣៤៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៦

លេខ ៣១១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកត/០៧០៦/៣២៧

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោធិកាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ :

ឯកឧត្តម នាយឧត្តមសេនីយ៍ **ឯម សំអាន**

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេរីវឌ្ឍន៍**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល-០៦០៧.៣៤៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០០៦

លេខ: ៣០៩ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៦/៣៧៩

ស្តីពី

ការកែប្រែព្រំប្រទល់រវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល

~~~~~~~

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៦ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
~~~~~~~

ព្រះរាជក្រឹត្យ

មាត្រា ១.-

ត្រូវបានកែប្រែព្រំប្រទល់រវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល ដោយកាត់យកភូមិអង្គ ភូមិរលួដីម ភូមិអង្គកែវ និងភូមិព្រៃស្វាយក្នុងឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល មកជាភូមិអង្គ ភូមិអូដីម ភូមិអង្គកែវ និងភូមិព្រៃស្វាយ ចំណុះសង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣.-

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០០៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត/០៧០៦/៣៥០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

លេខ : ៣៦២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

13e

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៧២ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៥ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន **៦០០** លានរៀល (ប្រាំមួយរយលានរៀលគត់) ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) ជូនព្រឹទ្ធសភាសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រភេទ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចំណាយលើ សំភារៈការិយាល័យ ការសិក្សាពិសោធន៍ និង សោហ៊ុយទទួលភ្ញៀវ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់ វិទ្យាស្ថាន សហព័ន្ធ អ៊ីរ៉ុប

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី-១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទិ ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ២៦៣៦ អយក.ឧស ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៦

ស ម្រេ ច

មាត្រា ១ : ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប "Institute of European Union" ហៅកាត់ជាភាសាខ្មែរ "វ.ស.អ" និងហៅកាត់ជាភាសាអង់គ្លេស I.E.U ។

មាត្រា ២ : វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប មានទីតាំងស្ថិតនៅ អគារលេខ ១៧៣ស្ទួន ផ្លូវលេខ ១៨២ សង្កាត់ផ្សារដេប៉ូ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៣ : វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង សិក្សារយៈពេល ២ឆ្នាំ និងបរិញ្ញាបត្រ សិក្សារយៈពេល ៤ឆ្នាំ និងបរិញ្ញាបត្រជាន់ខ្ពស់ សិក្សាស្រាវជ្រាវ រយៈពេល ២ឆ្នាំ ជាមធ្យម។ ក្នុងរយៈពេល បីខែ បន្ទាប់ពីថ្ងៃចាប់ដំណើរការ វិទ្យាស្ថាននេះ ត្រូវរៀបចំកម្មវិធីសិក្សាលំអិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៤ : វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប មានមហាវិទ្យាល័យចំនួន ០៤ :

- មហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ និងភាសាបរទេស
- មហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន
- មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងនីតិសាស្ត្រ
- មហាវិទ្យាល័យគ្រប់គ្រង និងទេសចរណ៍

ទៅអនាគត វិទ្យាស្ថាននេះ អាចបើកសាខា មហាវិទ្យាល័យ មុខជំនាញ ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៥ : វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

មាត្រា ៦ : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃវិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៧ : វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប ត្រូវគោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ ឱ្យបានល្អប្រសើរ។

មាត្រា ៨ : នាយកនៃវិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប មានភារកិច្ចទទួលខុសត្រូវ ចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន ធានាឱ្យបាននូវសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

មាត្រា ៩ : និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងឯកទេស ដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយវិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួង អប់រំ យុវជន និងកីឡា។

មាត្រា ១០ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និង វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១០
- រាជកិច្ច ✓

ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥២១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូន គ្រឿង ឥស្សរិយយស

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនដ៏មានតម្លៃជូនដល់កាកបាទក្រហមកម្ពុជា ដើម្បីបំរើសកម្មភាពមនុស្សធម៌ របស់កាកបាទក្រហមកម្ពុជាកន្លងមក ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **សុខ ចំរើន**

២-លោកជំទាវ **សេខ គាខ**

៣-លោក **ជា សុខ**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥២២ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រី ចំនួន០៧រូប បំរើការងារនៅក្នុងគម្រោង PRIP ដែលមានស្នាដៃល្អក្នុងការខិតខំប្រឹងប្រែងពុះពារសំរេចភារកិច្ច ស្តារហេដ្ឋារចនាសម្ព័ន្ធ ខេត្ត និងជនបទ នៅភូមិភាគឧត្តរ (កំពង់ធំ សៀមរាប ព្រះវិហារ និង ឧត្តរមានជ័យ) ដូចមានរាយនាមខាងក្រោម :-

១-លោក	**ឌុក**	**ណារិន**	នាយកប្រតិបត្តិការ គំរោង PRIP
២-លោក	**ណៃ**	**ចំណង់**	វិស្វករ គំរោង PRIP
៣-លោក	**គីម**	**ម៉ុន្ណារ៉ា**	លទ្ធកម្ម គំរោង PRIP
៤-លោក	**ម៉ៅ**	**ឡារ៉ិច**	ប្រធាន គំរោង PRIP ខេត្ត កំពង់ធំ
៥-លោក	**សុខ**	**ស៊ុនលីន**	ប្រធាន គំរោង PRIP ខេត្ត សៀមរាប
៦-លោក	**ផាន់**	**សំអាន**	ប្រធាន គំរោង PRIP ខេត្ត ព្រះវិហារ
៧-លោក	**ឃួន**	**សែ**	ប្រធាន គំរោង PRIP ខេត្ត ឧត្តរមានជ័យ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៥២៣...អនក្រ-បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ
ឧ០ឡ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូននាយទាហាន និង មន្ត្រីរាជការ ចំនួន៥០ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

១-វរសេនីយ៍ឯក	ខៀវ	សេនពិសិដ្ឋ	នាយរងសេនាធិការកងពលតូច លេខ ៧០
២-វរសេនីយ៍ទោ	ហ៊ឹម	សុផន្ន	នាយរងផ្នែកលេខាធិការដ្ឋាន កងពលតូចលេខ ៧០
៣-វរសេនីយ៍ទោ	ពន	សុវណ្ណារ៉ែត	នាយការិយាល័យទី២ កងពលតូចលេខ ៧០
៤-វរសេនីយ៍ទោ	ឡាច	រ៉ាម៉ន	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
៥-វរសេនីយ៍ត្រី	កេន	រ៉ាវី	អង្គរក្ស កងពលតូចលេខ ៧០
៦-វរសេនីយ៍ត្រី	ផាន់	ចន្ថា	អង្គរក្ស កងពលតូចលេខ ៧០
៧-វរសេនីយ៍ត្រី	លឹម	ដាហេង	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
៨-វរសេនីយ៍ត្រី	សោម	យ៉ិន	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
៩-វរសេនីយ៍ត្រី	សុខ	សុធីរៈ	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
១០-វរសេនីយ៍ត្រី	ចាន់	សុគា	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
១១-វរសេនីយ៍ត្រី	លី	ម៉េងហុង	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
១២-វរសេនីយ៍ត្រី	ហួត	ឈាងអន	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០

១៣-វរសេនីយ៍ត្រី	ម៉ុន	ចាន់នី	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
១៤-វរសេនីយ៍ត្រី	សេង	ពិសិដ្ឋ	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
១៥-វរសេនីយ៍ត្រី	ចាង	ឌី	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
១៦-វរសេនីយ៍ត្រី	ឃុត	ចំនឈីកៈ	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
១៧-វរសេនីយ៍ត្រី	ឈីម	ចាន់ថេង	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
១៨-លោក	អ៊ូ	ណាម	
១៩-វរសេនីយ៍ត្រី	សំ	ណាង	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
២០-វរសេនីយ៍ត្រី	ឈ៉ឹម	ស៊ុមយ៉ាង	នាយរងការិយាល័យទី២ កងពលតូចលេខ ៧០
២១-អនុសេនីយ៍ឯក	ឃុន	សុចិត្រ	ជំនួយការការិយាល័យទី២ កងពលតូចលេខ ៧០
២២-អនុសេនីយ៍ឯក	អ៊ុង	ហៀង	ជំនួយការ ឯកឧត្តម ឱម យិនទៀង
២៣-អនុសេនីយ៍ឯក	អ៊ូរ	ចន់ឌី	ជំនួយការការិយាល័យទី ៣ កងពលតូចលេខ ៧០
២៤-អនុសេនីយ៍ឯក	ខ្សែ	ស៊ីថា	ជំនួយការការិយាល័យទី ៤ កងពលតូចលេខ ៧០
២៥-អនុសេនីយ៍ឯក	សៅ	ខាន់	ជំនួយការការិយាល័យទី ៤ កងពលតូចលេខ ៧០
២៦-អនុសេនីយ៍ឯក	ឆៃ	ឃីវ	ជំនួយការការិយាល័យទី ៤ កងពលតូចលេខ ៧០
២៧-អនុសេនីយ៍ឯក	ទ៊ុង	ឈីដា	ជំនួយការការិយាល័យទី ៤ កងពលតូចលេខ ៧០
២៨-អនុសេនីយ៍ឯក	អ៊ូរ	សៅឌី	ជំនួយការការិយាល័យទី ៤ កងពលតូចលេខ ៧០
២៩-អនុសេនីយ៍ឯក	ឡាំ	ថេង	ជំនួយការការិយាល័យទី ៤ កងពលតូចលេខ ៧០
៣០-អនុសេនីយ៍ឯក	ច្រាយ	គីញ	ជំនួយការការិយាល័យទី ២ កងពលតូចលេខ ៧០
៣១-អនុសេនីយ៍ឯក	នៅ	យ៉ាល់	បើកបរ កងពលតូចលេខ ៧០
៣២-អនុសេនីយ៍ឯក	នៅ	ឡាំង	បើកបរ កងពលតូចលេខ ៧០
៣៣-អនុសេនីយ៍ឯក	សេង	សាន្ត	បើកបរ កងពលតូចលេខ ៧០
៣៤-អនុសេនីយ៍ឯក	ខឹម	ផល្លី	អង្គរក្ស កងពលតូចលេខ ៧០
៣៥-អនុសេនីយ៍ឯក	ផៃ	ម៉ាណែត	អង្គរក្ស កងពលតូចលេខ ៧០
៣៦-អនុសេនីយ៍ឯក	ស៊ិន	កុសល	អង្គរក្ស កងពលតូចលេខ ៧០
៣៧-អនុសេនីយ៍ឯក	សម្បត្តិ	ហ៊ូណា	ជំនួយការ ឯកឧត្តម ឱម យិនទៀង
៣៨-អនុសេនីយ៍ឯក	ហឿន	ទីណា	
៣៩-លោកស្រី	ទូល	ភាន	
៤០-លោក	មាស	ធាវី	
៤១-លោក	ដួង	សារិទ្ធ	
៤២-លោក	ប្រាក់	សារ៉ិន	
៤៣-អនុសេនីយ៍ទោ	ចិន	បឿន	អង្គរក្ស កងពលតូចលេខ ៧០
៤៤-អនុសេនីយ៍ទោ	ទាះ	ណារ៉ែន	ជំនួយការការិយាល័យទី ៥ កងពលតូចលេខ ៧០
៤៥-អនុសេនីយ៍ទោ	ឃួន	សេងភឿន	ជំនួយការការិយាល័យទី ៥ កងពលតូចលេខ ៧០

៤៦-អនុសេនីយ៍ទោ	ឆ្នាំ	ម៉ុន្ណារ៉ា	ជំនួយការការិយាល័យទី ៥ កងពលតូចលេខ ៧០
៤៧-អនុសេនីយ៍ទោ	ចាន់	សីហា	បើកបរ កងពលតូចលេខ ៧០
៤៨-អនុសេនីយ៍ទោ	ហេង	កុសល	ជំនួយការផ្នែកលេខាធិការដ្ឋាន កងពលតូចលេខ ៧០
៤៩-អនុសេនីយ៍ទោ	ចាន់	ទិន្ន	ជំនួយការការិយាល័យទី ៥ កងពលតូចលេខ ៧០
៥០-អនុសេនីយ៍ទោ	មុំ	សាន	ជំនួយការការិយាល័យទី ៥ កងពលតូចលេខ ៧០

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ......៥៦៧៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ
៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន១៧រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសការងារ :

១- លោក	ម៉ូរ៉ា វិណា	នាយខុទ្ទកាល័យសាលាខេត្ត ស្វាយរៀង
២- លោក	ឡុង សារិន	អនុប្រធាននាយកដ្ឋានប្រៃសណីយ៍ និង ទូរគមនាគមនីក្នុងប្រទេស
៣- លោក	អ៊ុយ ផន	អភិបាលស្រុក ស្វាយជ្រំ ខេត្តស្វាយរៀង
៤- លោក	ញឹម ឡាស់	អភិបាលរងស្រុក ស្វាយជ្រំ ខេត្តស្វាយរៀង
៥- លោក	នេត លី	អភិបាលរងស្រុក ស្វាយជ្រំ ខេត្តស្វាយរៀង
៦- លោក	យស់ គឹមស៊ន	អភិបាលរងស្រុក ស្វាយជ្រំ ខេត្តស្វាយរៀង
៧- លោក	ហ៊ឹ វត្ថនៈ	ប្រធានហិរញ្ញវត្ថុ ខេត្តស្វាយរៀង
៨- លោក	ឃុន ម៉ូដាន់	អនុប្រធានហិរញ្ញវត្ថុ ខេត្តស្វាយរៀង

ខ.មេជាយថ្នាក់ការខារ :

១- លោក **ម៉ុក អាយ** មេឃុំដូនសរ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

២- លោក **ស្រី សាផុន** មេឃុំធ្លក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

គ.មេជាយសីវិល្លការខារ :

១- លោក **សុខ ជន** មេឃុំអង្គតាសូ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

២- លោក **ហុង ឌុច** មេឃុំស្វាយយា ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

៣- លោក **ខួន យ៉េន** មេឃុំស្វាយអង្គ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

៤- កញ្ញា **នេត សោម្ភន្ធ** មេឃុំគោកព្រីង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

៥- លោក **ឡឹក ឃុន** មេឃុំពោធិរាជ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

៦- លោក **ម៉ែន រុន** មេឃុំក្រោលគោ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

៧- លោក **សុខ ចេង** ប្រធានការិយាល័យបេតិកភ័ណ្ឌ នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តស្វាយរៀង

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៥៤២៥.....អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ប្រគេនព្រះតេជគុណ **ងុំ សយ** ព្រះវិន័យធរ អនុគណស្រុកស្វាយជ្រំ និង ជាព្រះចៅអធិការវត្តល្វើន ឃុំដូនសរ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដែលមានស្នាព្រះហស្តល្អ ក្នុងការដឹកនាំកសាង សមិទ្ធផល ក្នុងព្រះពុទ្ធសាសនា និងសង្គម ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៦
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តព្រៃវែង

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៩ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន សំរាប់ចូលរួមកសាងសមិទ្ធផលនានា នៅវត្តប្រជីសដ្ឋាន ក្នុងឃុំជីពូន ស្រុកព្រៃវែង ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-លោក	**គង់ ប៊ុនឈឿន** និងអ្នកស្រី **ក្អួយ ខ្សៀវចិន**		ថវិកាចំនួន ១៨.៧០០ ដុល្លារ
២-លោកយាយ	**លន់ គត់**		ថវិកាចំនួន ១២.០០០ ដុល្លារ
៣-លោក	**លី ម៉េងលាង**		ថវិកា ចំនួន ១២.០០០ ដុល្លារ
៤-លោក	**លី លាង**		ថវិកា ចំនួន ១២.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក	**ជ្រឹន យ៉ាន**		ថវិកា ចំនួន ៥.០០០ ដុល្លារ
២-លោកយាយ	**ឡូច រី**		ថវិកា ចំនួន ៥.០០០ ដុល្លារ
៣-លោក	**នូ អ៊ែល**	គណៈកម្មការសាងសង់	
៤-លោក	**នូ ហែល**	គណៈកម្មការសាងសង់	
៥-លោក	**ហេង ហៃ**	គណៈកម្មការសាងសង់	

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥២៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

សម្រេច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ចលោក **សួស សារ៉េត** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ ពីអភិបាលស្រុកថ្មបាំង អោយទៅបំរើការងារនៅសាលាខេត្តកោះកុង ដោយរក្សា ឋានន្តរសក្តិ និង ថ្នាក់ដដែល ។

មាត្រា ២ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ទូ សាទុន** ឋានន្តរស័ក្តិ វរសេនីយ៍ត្រី នៃក្របខ័ណ្ឌមន្ត្រីកងយោធពលខេមរភូមិន្ទ ជាអភិបាលស្រុកថ្មបាំង ខេត្តកោះកុង ។

មាត្រា ៣ : លោក **ទូ សាទុន** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួន ត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៥២៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក ជួន ជីវិន ជាជំនួយការ ឯកឧត្តម ស៊ាន បូរ៉ាត ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២៩. អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខងារ នាយទាហាន

៚៚✳៚៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពី ការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

១-ឧត្តមសេនីយ៍ទោ **សែម សុវណ្ណនី** អត្តលេខ ០០០៣១០ ជា នាយរងសេនាធិការចំរុះ និងជានាយកមជ្ឈមណ្ឌលបោសសំអាតមីនយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឧត្តមសេនីយ៍ទោ **មាន់ សុខុម** អត្តលេខ ០០០២៨៦ ជា នាយក មជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធ-សាស្ត្រយោធា អគ្គបញ្ជាការដ្ឋាន

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៥៣០...អនក្រ.ឧក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
១៧
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូននាយទាហាន និងមន្ត្រីរាជការ ចំនួន ៣៥រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួម កសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ដូចមានរាយនាមខាងក្រោម :-

ក. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ឯកឧត្តម ឧត្តមសេនីយ៍ឯក	មាស	សាម៉ន	អគ្គនាយក អគ្គនាយកដ្ឋាន យោធសេវាក្រសួងការពារជាតិ
២-ឯកឧត្តម	ម៉ៅ	ភិរុណ	អភិបាលរង ខេត្តកណ្តាល
៣-ឧកញ៉ា	ថៃ	សេងឡុង	នាយកក្រុមហ៊ុន ហួត ត្រាកូ
៤-លោកវរសេនីយ៍ឯក	អ៊ុក	សុទ្ធសេន	នាយរងការិយាល័យ ព្រំដែនកងទ័ពជើងគោក
៥-លោក វរសេនីយ៍ឯក	ហួត	គីមសាន	ជំនួយការឯកឧត្តម **ហ៊ីង ប៊ុនហៀង** នាយរងសេនាធិការចំរុះ
៦-លោក វរសេនីយ៍ឯក	សុខ	សារ	ជំនួយការឯកឧត្តម **ហ៊ីង ប៊ុនហៀង** នាយរងសេនាធិការចំរុះ
៧-លោក វរសេនីយ៍ឯក	ស៊ិន	ហួរ	ជំនួយការឯកឧត្តម **ហ៊ីង ប៊ុនហៀង** នាយរងសេនាធិការចំរុះ
៨-លោក	ចាប	ហុងលី	ជំនួយការឯកឧត្តម **ហ៊ីង ប៊ុនហៀង** នាយរងសេនាធិការចំរុះ

ខ. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១-ឯកឧត្តម ឧត្តមសេនីយ៍ទោ	កែវ	សាមួន	មេបញ្ជាការយោធភូមិភាគទី៣
២-ឯកឧត្តម	ស្រី	ថេន	អភិបាលខេត្តតាកែវ

៣-លោក ឧត្តមសេនីយ៍ត្រី	យង់	សារិទ្ធ	មេបញ្ជាការរងកងឯកភាពអង្គរក្ស
៤-លោក ឧត្តមសេនីយ៍ត្រី	ជា	លន	នាយរងសេនាធិការ កងឯកភាពអង្គរក្ស
៥-លោក ឧត្តមសេនីយ៍ត្រី	នៅ	សាខិន	នាយរងសេនាធិការ កងឯកភាពអង្គរក្ស
៦-លោក ឧត្តមសេនីយ៍ត្រី	លឹម	សុធា	នាយរងសេនាធិការ កងឯកភាពអង្គរក្ស
៧-លោក វរសេនីយ៍ឯក	សាយ	សារុន	មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករង តាកែវ
៨-លោក វរសេនីយ៍ឯក	ឡា	ឡៃ	មេបញ្ជាការកងរាជអាវុធហត្ថ ខេត្តតាកែវ
៩- លោក វរសេនីយ៍ឯក	យ៉ាត	រិទ្ធ	នាយរងការិយាល័យអភិវឌ្ឍន៍កងឯកភាពអង្គរក្ស
១០-លោកវរសេនីយ៍ឯក	យ៉ាត	ឡូច	ជំនួយការឯកឧត្តម **ហ៊ុន ម៉ុនៈម៉ៅ** នាយរងសេនាធិការចំរុះ
១១-លោកវរសេនីយ៍ឯក	ប្រាជ្ញ	សុផល	ជំនួយការឯកឧត្តម **ហ៊ុន ម៉ុនៈម៉ៅ** នាយរងសេនាធិការចំរុះ
១២-លោកវរសេនីយ៍ទោ	ស្រេង	ហុង	មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត កោះកុង
១៣-លោកវរសេនីយ៍ទោ	ប៉េ	សុខណ្ណរជេត	មេបញ្ជាការរង អ.ហ នៃកងឯកភាពអង្គរក្ស
១៤-លោក វរសេនីយ៍ត្រី	ថៅ	គៀន	ជំនួយការឯកឧត្តម **ហ៊ុន ម៉ុនៈម៉ៅ** នាយរងសេនាធិការចំរុះ
១៥-លោកវរសេនីយ៍ត្រី	ពៅ	ថាវិទ្ធ	ជំនួយការឯកឧត្តម មេបញ្ជាការកងឯកភាពអង្គរក្ស
១៦-លោកវរសេនីយ៍ត្រី	កៅ	រតនា	ជំនួយការឯកឧត្តម ចៅ តុល នាយករង ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
១៧-លោក	ឡឿង	ឆាលី	អគ្គលេខាធិការ គណៈកម្មាធិការសម្របសម្រួលកម្ពុជា
១៨-លោក	អំ	ម៉ុនលី	ប្រធានការិយាល័យ ដែនដី នគរូបនីយកម្មនិងសំណង់ខណ្ឌទួលគោក
១៩-លោក	ជា	ស្រួយ	ប្រធានក្រុមប្រឹក្សាឃុំ ព្រែកថ្មី ស្រុកគៀនស្វាយ ខេត្តកណ្តាល
២០-លោក	សរ	លន់	ប្រធានគណៈកម្មការសាងសង់វត្តអម្ពរវ័ន្ត
២១-លោក	ឈឹម	ឡាយ	ប្រធានគណៈកម្មការវត្តអម្ពរវ័ន្ត
២២-លោក	ជុំ	ថាន	ប្រធានក្រុមជាងវត្តអម្ពរវ័ន្ត
២៣-លោក	ម៉ម	ខូន	ក្រុមការងារសាងសង់ព្រះវិហារវត្តអម្ពរវ័ន្ត
២៤-លោក	ហ៊ុយ	លី	ក្រុមប្រឹក្សាឃុំព្រែកថ្មី ស្រុកគៀនស្វាយ ខេត្តកណ្តាល
២៥-លោក	អ៊ុំ	សេង	មេឃុំ អន្លង់រាប ស្រុកវាលវែង ខេត្តពោធិសាត់
២៦-លោក	ឈឹម	សាំង	សមាជិកក្រុមប្រឹក្សាឃុំព្រែកថ្មី ស្រុកគៀនស្វាយ ខេត្តកណ្តាល
២៧-លោកអនុសេនីយ៍ទោ	ម៉ែន	សារិ	បញ្ជាការដ្ឋានកងឯកភាពអង្គរក្ស សម្តេច **ហ៊ុន សែន**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៣១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យ លេខ ៦៧ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យ លេខ ៣១ អនក្រ/បក ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យ លេខ ១៨ អនក្រ/បក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តនីការផ្លាស់ប្តូរឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១.-

ត្រូវបានតែងតាំងលោក **ខា គីមឡុង** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋានក្រសួងសុខាភិបាល ។

មាត្រា ២.-

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រី ចំនួន ០៤ រូប នៃក្រសួងសុខាភិបាល ដែលមាន រាយនាមដូចខាងក្រោម÷

១. លោក **ម៉ី សំបូរ** ឱ្យបំពេញមុខងារជា ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក នៃក្រសួងសុខាភិបាល

២. លោក **ឡាយ ឃួន** ឱ្យបំពេញមុខងារជា ប្រធាននាយកដ្ឋានថវិកានិងហិរញ្ញវត្ថុនៃក្រសួងសុខាភិបាល

៣. លោកស្រី **ខិ វណ្ណឌីន** ឱ្យបំពេញមុខងារជា ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងសុខាភិបាល

៤. លោក **អ៊ីច សុមុណ្ណ** ឱ្យបំពេញមុខងារជា ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសុខាភិបាល ។

មាត្រា ៣.-

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និង មាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៣៥...សសរ

សេចក្តីសំរេច
ស្តីពី
ការបង្កើតគណៈកម្មការអន្តរក្រសួង ដោះស្រាយបញ្ហាសំណង់ក្នុងបរិវេណវត្តនិរោធរង្សី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌

-បានឃើញអនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីការអនុវត្តច្បាប់កិច្ចការពារបេតិកភ័ណ្ឌវប្បធម៌

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

ប្រការ១: បង្កើតគណៈកម្មការអន្តរក្រសួង ដោះស្រាយវិវាទសំណង់ក្នុងបរិវេណវត្តនិរោធរង្សី សង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោមៈ

១. ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា **ប្រធាន**

២. ឯកឧត្តម **ប៊ុន សំ** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ **អនុប្រធាន**

៣. ឯកឧត្តម **ជុំច អឿន** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ **អនុប្រធាន**

៤. ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ **អនុប្រធាន**

៥. ឯកឧត្តម បណ្ឌិតរដ្ឋ **តិច សំណាង** អគ្គលេខាធិការ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (ទីស្តីការគណៈរដ្ឋមន្ត្រី) **អនុប្រធាន**

៦. ឯកឧត្តម **ឆាន់ សាផាន** រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ **សមាជិក**

៧. ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋលេខាធិការ ក្រសួងសាធារណការ និង ដឹកជញ្ជូន **សមាជិក**

៨. ឯកឧត្តម **ប្រាជ្ញ ស៊ុន** រដ្ឋលេខាធិការ ក្រសួងបរិស្ថាន **សមាជិក**

៩. ឯកឧត្តម **សៅ សុខា** អគ្គបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស **សមាជិក**

១០. ឯកឧត្តម **កែប ជុតិមា** អភិបាលរាជធានីភ្នំពេញ **សមាជិក**

១១. លោក **តួច ចំរើន** អភិបាលខណ្ឌមានជ័យ **សមាជិក**

ប្រការ២: ប្រធានគណៈកម្មការមានសិទ្ធិជ្រើសរើសលេខាមួយរូប ក្នុងក្រសួងធម្មការ និង សាសនា ដើម្បីជួយការងាររបស់ខ្លួន ។

ប្រការ៣: គណៈកម្មការនេះ មានតួនាទីភារកិច្ច ដូចខាងក្រោម :

-ធ្វើការពិភាក្សា និងសម្របសម្រួល ជាមួយប្រជាពលរដ្ឋ និងគណៈកម្មការសាងសង់ ដើម្បីដោះបញ្ហានេះដោយសន្តិវិធី

-សិក្សាបច្ចេកទេស និងការចំណាយសំរាប់សំណង់ដែលត្រូវរើរចោល និងការរំកិលសំណង់ពាក់ព័ន្ធមកទីតាំងថ្មី

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ជូនរាជរដ្ឋាភិបាល ។

ប្រការ៤: គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រា ក្រសួងធម្មការ និងសាសនា ដើម្បីសំរួលការងារ ។

ប្រការ៥: សមាជិកទាំងអស់ត្រូវចូលរួមប្រជុំ និងចុះបំពេញភារកិច្ច តាមការអញ្ជើញ និងការចាត់តាំង របស់ប្រធានគណៈកម្មការ ។

ប្រការ៦: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១៤៥៧ ពណ.នគក

ភ្នំពេញថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហៀង គាត អ៊ីមផត អិចផត**

HEANG KEAT IMPORT EXPORT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8741/06P ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **សុខ ស៊ើន**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ A១៧ ផ្លូវលេខ ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ

-ពិសេសនាំចូលគ្រឿងសង្ហារឹម ពូកអេប៉ុង សំភារៈ កីឡា ឧបករណ៍នេសាទគ្រប់ប្រភេទ គ្រឿងម៉ាស៊ីន ឧបករណ៍ និងគ្រឿងបន្លាស់គ្រប់ប្រភេទ សំរាប់បំរើអោយវិស័យកសិកម្មនិងឧស្សាហកម្ម កុំព្យូទ័រ គ្រឿងអគ្គីសនីនិងគ្រឿងបន្លាស់ គ្រឿងសំអាងកាយ ឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ ចំណីសត្វ ថ្នាំព្យាបាលសត្វ ថ្នាំសំលាប់សត្វល្អិត

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ ពេជ្រ ត្បូងថ្មមានតំលៃគ្រប់ប្រភេទ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន-សេវាជួយធ្វើបែបបទអាហារ័ណនីហារ័ណទំនិញ

- សាងសង់ ផ្លូវថ្នល់ អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ពិសេសផលិត គ្រឿងសង្ហារឹម ពូកអេប៉ុង គ្រឿងសំអាងកាយ ចំណីសត្វ ថ្នាំព្យាបាលសត្វ ថ្នាំសំលាប់សត្វល្អិត - សិប្បកម្មកែច្នៃកសិផល រុក្ខផលនិងជលផលសំរាប់នាំចេញ

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម_ប្រសិទ្ធ

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល-ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន-ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៤៥៥ ពណ.នគក

ភ្នំពេញថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **បេស ត្រេនស្ព័ត & សឺវីស**
BEST TRANSPORT & SERVICES Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8722/06P** ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ជា សុខហេង**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៦ D ផ្លូវលេខ ៣៦៦ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការដូសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងដឹកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

- សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ស៊ីថា

ចាម ប្រសិទ្ធ

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៤៥៥ ពណ.នគក

ភ្នំពេញថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ជំរាបមក

លោក ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន OGILVY & MATHER (VIETNAM) LTD.

អាស័យដ្ឋាន : Sun Wah Tower 16th Floor 115 Nguyen Hue Boulevard District 1 Ho Chi Minh City Viet Nam.

កម្មវត្ថុ : ករណីសុំបង្កើតការិយាល័យតំណាងក្រុមហ៊ុន **អូជីវី & ម៉ាធើរ (វៀតណាម)** Representative Office Of OGILVY & MATHER (VIETNAM) LTD. ប្រចាំរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា

យោង : សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបលោកជ្រាបថា : ក្រសួងពាណិជ្ជកម្មអនុញ្ញាតជាគោលការណ៍អោយបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន **អូជីវី & ម៉ាធើរ (វៀតណាម)** Representative Office Of OGILVY & MATHER (VIETNAM) LTD. ប្រចាំរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាដែលបានចុះបញ្ជី នៅប្រទេសវៀតណាម មាន លោក PHAN DANNY កាន់លិខិតឆ្លងដែន លេខ 112856469 ចុះថ្ងៃទី 13-11-2003 ជាអ្នកតំណាង និងមានទីស្នាក់ការតាំងនៅ ផ្ទះលេខ ៥៥ ផ្លូវលេខ ១៧៨ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

រាល់សកម្មភាពរបស់ការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុននេះ ត្រូវគោរពប្រតិបត្តិទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អាស្រ័យហេតុនេះ សូមលោកជ្រាបនិងអនុវត្តតាមការសមស្រប ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចម្លងជូន :

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៤៥៦ ពណ.នគក

ភ្នំពេញថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ឡាក់ឃីរេ អាយ អិន ធី**
LuckyRay INT Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 2949/06E** ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **.OKEREKE NWABUEZE RAYMOND**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ១៣ ផ្លូវលេខ ២៨២ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -[illegible] ចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ .

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ឧទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ឧទ្ទីស្តីធី

 គឹម ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៤៥៧ ពណ.ឧតក

ភ្នំពេញថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៦

